# ការបង្កើតផែនដីកាលពី៤ពាន់លានឆ្នាំមុនតាមសំណេរសោមា

តាមសំណេរលើផ្ទាំងឥដ្ឋទី៧ ក្នុងចំណោមសំណេរផ្ទាំងឥដ្ឋចំនួនជាង២ពាន់ផ្ទាំងដែលគេបានរកឃើញនៅនីនីវនៅឆ្នាំ១៩៣០ សរសេរទាក់ទងនឹងការបង្កើតផែនដីកាលពី៤ពាន់លានឆ្នាំមុន។ តាមសំណេរនេះ ផែនដីដើមគ្របដណ្តប់ដោយទឹកប្រៃ ដែលសោមាហៅថា ទីយ៉ាម៉ាត មានទំហំពីរដងធំជាងផែនដីបច្ចុប្បន្ន រត់ក្នុងគន្លងព្រះអាទិត្យ ចន្លោះភពយូពីទ័រ និងភពម៉ាស់(អង្គារ) តែកាលពី៤ពាន់លានឆ្នាំកន្លង មានផ្កាយមួយឈ្មោះនីប៊ីរ៉ូ បានរត់មកក្បែរប្រព័ន្ធព្រះអាទិត្យ ហើយត្រូវបានប្រព័ន្ធព្រះអាទិត្យទាញស្រូបចូលកណ្តាលប្រព័ន្ធព្រះអាទិត្យ ពេលនោះផ្កាយរណបមួយរបស់នីប៊ីរ៉ូបានទង្គិចគ្នាជាមួយទីយ៉ាម៉ាត់(រូបទី១) ហើយបានបំបែកភពទីយ៉ាម៉ាត់ ជាបំណែកតូចៗជាច្រើន។ បំណែកធំបានត្រូវផ្កាយរណបរបស់នីប៊ីរ៉ូ រុញអោយធ្លាក់មកកន្លងថ្មីក្លាយជាផែនដីបច្ចុប្បន្ន(រូបភាពទី២) ឯបំណែកខ្លះទៀតនៃទីយ៉ាម៉ាត បានវិលប្រសព្វជាមួយបំណែកផ្កាយរណរបស់នីប៊ីរ៉ូ បង្កើតបានជាព្រះចន្ទ្រ ឯចំណែកតូចៗដែលមិនអាចមកជាមួយបំណែកធំនៅតែបន្តរត់លើកន្លងចាស់ ដែលយើងតែងហៅថា ខ្សែក្រវ៉ាត់នៃព្រះពន្ធ័ព្រះអាទិត្យ រត់នៅចន្លោះភពយូពីទ័រ និងម៉ាស់ដដែល(ceinture asteroideរូបទី៣) - ពេលបានរុញទីយ៉ាម៉ាតអោយធ្លាក់មកគន្លងថ្មី ផ្កាយរណបនីប៊ីរ៉ូ បន្តវិលលុញទីយ៉ាម៉ាតអោយមានទម្រង់ជាផែនដីបច្ចុប្បន្ន។

កាលពី៤៥០ពាន់ឆ្នាំមុន ពួកភពនីប៊ីរ៉ូ ដែលសោមាហៅថា អានូនាគី បានចុះមកផែនដីម្តងទៀត ដោយសារពួកគេត្រូវការមាសនិងរ៉ែផ្សេងទៀតយកទៅរោយការពារភពនីប៊ីរ៉ូ ព្រោះពួកគេបានដឹងថា នៅភពទីយ៉ាម៉ាត មានមាសច្រើននៅលើភពនេះ។ ពេលដែលគេមកដឹកជញ្ជូនមាសពីផែនដី ពួកអានូនាគី បានយកភពម៉ាស់ជាស្ថានីយ៍ឆ្លងរវាងនីប៊ីរ៉ូនិងផែនដីថ្មី ដែលបច្ចុប្បន្ន អ្នកវិទ្យាសាស្ត្របានថតបំណែកសំណល់ដែលអោយគេសន្និដ្ឋានថា ភពម៉ាស់ធ្លាប់មានជីវិតរស់នៅ។ ណាស៊ាទើបតែថតបានផ្ទាំងគំនូរលើផ្ទាំងថ្មភពម៉ាស់ដែលមានទម្រង់ស្រដៀងក្បាលមនុស្ស។ អ្វីដែលគួរអោយអស្ចារ្យនៅគឺ ផ្ទាំងឥដ្ឋចំណារសោមាបានកត់ត្រាទាក់ទងនឹងរូបក្បាលមនុស្សដែលណាស្សាថតបានពីភពម៉ាស់។ សំណេរបានសរសេរថាៈ នៅលើភ្នំដ៏ធំនៃភពអង្គារ/ម៉ាស់ គេបានឆ្លាក់រូបអាឡាលុយ ដោយកាំរស្មីពន្លឺ - មុខរបស់ទ្រង់បែរទៅភពនីប៊ីរ៉ូដែលទ្រង់ធ្លាប់សោយរាជ្យនិងទៅផែនដីដែលទ្រង់បានរកឃើញមាស។

សំណេរសោមា បានសរសេរបន្តថា ពេលដែលមករុករកមាសនៅផែនដី ពួកអានូនាគី ត្រូវការកម្លាំងពលកម្ម ពេលនោះគេបានឃើញពួកស្វានៅអាហ្វ្រិកដែលទំនងអាចយកមកប្រើការបាន ក៏បានធ្វើក្លូនជាមួយហ្សែនពួកគេដើម្បីបង្កើតមនុស្សថ្មីជាបន្តបន្ទាប់ រហូតដល់ជំនាន់ទី៧ ទើបបានជាមនុស្សដូចដែលគេចង់បាន គឺពូជមនុស្សអូម៉ូសាបព្យាង។ ពេលចប់បេសកម្ម ហើយពួកគេចង់ត្រូវត្រលប់ទៅភពនីប៊ីរ៉ូវិញ ពួកអានូនាគីខ្លះចង់សម្លាប់មនុស្សដែលគេបានបង្កើតវិញដោយធ្វើអោយមានទឹកជំនន់លិចផែនដី តែកាលណោះ មានអានូនាគីខ្លះ ពិសេស អង្គី មានសមានចិត្តចំណោះមនុស្ស ទើបបានជួយសង្គ្រោះស្តេចមួយអង្គ ឈ្មោះសូដ្រាឬនូអេក្នុងគម្ពីរប៊ីប..

ជាប្រពៃណីដើម នគរសោមាគេគោរពស្ត្រីជាធំ។ ដោយលែកព្រះតំបូងរបស់គេក៏ជាស្ត្រីដែរ គឺព្រះនាងនាគីនាគឬអ៊ីណាន់ណា ដែលគេចាត់ទុកជាម្ចាស់ទឹកម្ចាស់ដីនៃរាជធានីសោមា អ៊ុយរ៉ុក។ ព្រះនាងត្រូវបានគេគូរក្បែររូបពស់មួយគូរដែលរនែរមួលចូលគ្នា តំណាងបញ្ញាញាណ intelligence និងវិទ្យាសាស្ត្រ la science/le savoir និងហត្ថកម្មហ្សែន(Chromosome/la modification génétique) - ពស់ដែលតំណាងបញ្ញាញាណ ចំណេះដឹងវិទ្យាសាស្ត្រ ឬ ហត្ថកម្មហ្សែន បានក្លាយជារូបនាគឬពស់ ក៏គួរអោយខ្លាចតាមអារ្យធម៌ដែលចម្លងយកមកកែក្លាយរាប់ពាន់ឆ្នាំក្រោយ..។ នៅអ៊ឺរ៉ុបនិងក្នុងពិភពលោកទាំងមូល គេបានយកសញ្ញានេះ តំណាងវិទ្យាសាស្ត្រ(ការត្រាស់ដឹង) និងសញ្ញានៃវិទ្យាស្ថានថ្នាំពេទ្យ។ និមិត្តរូបព្រះនាងនិងរូបព្រះនាង ត្រូវបានប្រជាជាតិជាច្រើន ជាពិសេសនៅមជ្ឈឹមបូព៌ានៅឥណ្ឌា។ល។ យកទៅចរនា និងគោរពតាមបែបផែនផ្សេងៗ ប្លែកៗតាមការយល់ឃើញរបស់គេ....។ ប្រពៃណីពិសិដ្ឋដើមមួយទៀតរបស់សោមាដែលបញ្ជាក់ពីប្រជាជាតិមាតាធិបតេយ្យរបស់នគរនេះ គឺគេតម្រូវអោយគ្រប់មហាក្សត្រសោមាដែលឡើងសោយរាជ្យជាស្តេច រៀបអភិសេកពិសិដ្ឋជាមួយព្រះនាងអ៊ីណាន់ណា ដែលគេអោយឈ្មោះថា ប្រពៃណីអាពាហ៍ពិពាហ៍ពិសិដ្ឋ។ គឺអាពាហ៍ពិពាហ៍រវាងក្សត្រអធិរាជ្យជាមួយអទិទេព នាគីឬអ៊ីណាន់ណា។ ប្រពៃណីនេះ ត្រូវបានពួកក្សត្រក្រោយៗបំបាត់ចោល ហើយបានធ្វើបដិវត្តផ្តួលរំលុំឥទ្ធិពលស្ត្រីទាំងក្នុងសង្គមសោមានិងក្នុងតំបន់ទាំងមូល ដែលបានបន្តជះឥទ្ធិពលរហូតដល់បច្ចុប្បន្ន។ ពួកក្រិក រ៉ូម៉ាំង សេមីត ។ល។ ដែលចម្លងមនោគមន៍ពីពួកបដិវត្តន៍នៅបាប៊ីឡូនបានរៀបចំសង្គមគេតាមបែបបិតាធិបតេយ្យ។ ទោះយ៉ាងណា ពួកជ្វីស នៅបន្តទុកស្ត្រីជាធំក្នុងប្រពៃណីខ្លះរបស់គេ ជាពិសេសទាក់ទងនឹងការបន្តពូជឬបន្តប្រជាជាតិជ្វីស.. ចន្ទ្រ

១១កុម្ភៈ២០២១


1
Jupiter
Tiamat
Nibiru
Mars


2
Mars
Tiamat


3
ceinture
d'astéroïdes
L'AGE D'OR